01363798

E393/4

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 12 / 2016
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចនៅលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យទទួលយកបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ និង ឯកសារចំនួនបួនពីមន្ទីរសន្តិសុខ ស-២១ ធ្វើជាឯកសារភ័ស្តុតាង (ឯកសារ E393/3)

១. អង្គជំនុំជម្រះបានទទួលសំណើមួយពីសហសហព្រះរាជអាជ្ញាសុំឱ្យទទួលយក (១) បញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលរាយឈ្មោះអ្នកទាំងឡាយដែលពុំមានឈ្មោះនៅក្នុងបញ្ជីដែលការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) បានបង្កើតឡើង និង (២) ឯកសារចំនួនបួនបន្ថែមទៀតពីមន្ទីរសន្តិសុខ ស-២១ (ឯកសារ E393/3)។

២. ជាសារវតារ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាបានដាក់បញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ក្នុងសំណុំរឿង ០០១ ដែលបង្ហាញឈ្មោះចំនួន ១២.២៧៣ ដោយមានការបញ្ជាក់ដោយឯកសារពីសម័យខ្មែរក្រហម(“បញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ព”)ដែលបន្ទាប់មកអង្គជំនុំជម្រះបានទទួលយកដោយដាក់លេខយោងជាឯកសារ E3/342 (ឯកសារ E185.1 ទំព័រ ១៩)។ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងមកអង្គជំនុំ

ជម្រះថា ក្រោមការគ្រប់គ្រងរបស់ប្រធានក្រុមវិភាគនៅ ក.ស.ច.ស អ្នកវិភាគម្នាក់ធ្វើការនៅ ក.ស.ច.ស បានបង្កើតបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដោយផ្អែកលើឯកសារពីសម័យខ្មែរក្រហមដែលត្រូវបានប្រមូលពីសារៈមន្ទីរទួលស្លែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា ("បញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស") (ឯកសារ E393)។ តាមការផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះបានទទួលយកបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស (ឯកសារ E393.2) និងបញ្ជីឯកសារចំនួន ៨៧១ ដែល ក.ស.ច.ស យកមកសំអាង ដើម្បីបង្កើតបញ្ជីឈ្មោះនេះ (ឯកសារ E393.3)។ ក្រោយមក អង្គជំនុំជម្រះបានទទួលយកឯកសារទាំងអស់ដែលជាមូលដ្ឋានសម្រាប់ធ្វើបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស ដែលកាលពីមុនមក ពុំទាន់បានទទួលយកធ្វើជាឯកសារភស្តុតាងនៅឡើយ (ប្រតិចារិកសវនាការថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ៤១-៤២) ។ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្តល់បញ្ជីឯកសារទាំងនេះដល់ភាគី (ឯកសារ E393/1; ឯកសារ E393/1.1)។

៣. នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់បញ្ជីមួយ ដែលមានឈ្មោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ចំនួន ១៦០៦ នាក់ ដែលពុំមានឈ្មោះនៅក្នុងបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលរៀបចំដោយ ក.ស.ច.ស នោះទេ ទោះបីវត្តមានអ្នកទាំងនោះនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានបង្ហាញតាមរយៈឯកសារបន្សល់ពីសម័យខ្មែរក្រហមយ៉ាងណាក៏ដោយ ("បញ្ជីឈ្មោះចំនួន ១ ៦០៦ នាក់") (ឯកសារ E393/2.1) និងបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាទៅលើបញ្ជីឈ្មោះនេះ នៅក្នុងការសម្រេចទៅលើចំនួនមនុស្សសរុបដែលត្រូវបានឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ (ឯកសារ E393/2 កថាខណ្ឌ ១)។ សហព្រះរាជអាជ្ញាក៏បានភ្ជាប់បញ្ជីឯកសារមួយ ដែល ក.ស.ច.ស ហាក់ដូចជាមិនបានយកមកពិចារណាឡើយ ដោយសារឯកសារនេះមិនស្ថិតនៅក្នុងបញ្ជីឯកសារចំនួន ៨៧១ ដែល ក.ស.ច.ស បានកត់សម្គាល់ថា មានការពាក់ព័ន្ធទៅនឹងការរៀបចំបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស (ឯកសារ E393.3)។ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យសហព្រះរាជអាជ្ញាបំភ្លឺថា តើសហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកបញ្ជីឈ្មោះអ្នជាប់ឃុំចំនួន ១៦០៦ នាក់ និង ឯកសារមូលដ្ឋាននានាធ្វើជាឯកសារភស្តុតាងដែរ ឬ ទេ។

៤. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកបញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ និងឯកសារពីសម័យខ្មែរក្រហមចំនួនបួនពីមន្ទីរសន្តិសុខ ស-២១ ដែលមានកត់ត្រាឈ្មោះអ្នកទាំងនោះ (ឯកសារ E393/3 កថាខណ្ឌ ១, ១០)។ សហព្រះរាជអាជ្ញាលើកឡើងថា បញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ មាននៅក្នុងបញ្ជីពីសម័យខ្មែរក្រហមចំនួន ៩២ នៅមន្ទីរសន្តិសុខ ស-២១ ដែលពុំមាននៅក្នុងបញ្ជីឯកសារបញ្ជាក់ចំនួន ៨៧១ របស់ ក.ស.ច.ស ទេ (ឯកសារ E393.3)។ សហព្រះរាជអាជ្ញាលើកឡើងថា ឯកសារចំនួនបួន ក្នុងចំណោមឯកសារទាំង ៩២ ពុំមាននៅក្នុងសំណុំរឿងនោះឡើយ ហើយសហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យទទួលយកឯកសារទាំងនេះ ធ្វើជាឯកសារភ័ស្តុតាង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ផងដែរ (ឯកសារ E393/3 កថាខណ្ឌ ៣, ១០)។ ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា បញ្ជីឈ្មោះ ១៦០៦ ព្រមទាំងឯកសារថ្មីចំនួនបួន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងឯកសារដែលមានក្នុងសំណុំរឿង ហេតុនេះហើយ ការទទួលយកឯកសារទាំងនេះធ្វើជាឯកសារភ័ស្តុតាងនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី គឺជាប្រយោជន៍នៃយុត្តិធម៌ (ឯកសារ E393/3 កថា-ខណ្ឌ ៧-៨)។

៥. មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ឯកសារពីសម័យខ្មែរក្រហមចំនួនបួន ដែលសហព្រះរាជអាជ្ញាបានស្នើសុំ ត្រូវបានទទួលយកធ្វើជាឯកសារភ័ស្តុតាងរួចហើយ។ ទោះជាយ៉ាងណាក្តី មេធាវីការពារក្តីកត់សម្គាល់ថា ឯកសារបន្ថែមមួយនៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំ ១៦០៦ នាក់ (ឯក-សារ D288/6.68.18) មិនទាន់ត្រូវបានទទួលយកធ្វើជាឯកសារភ័ស្តុតាងនៅឡើយ ហើយបញ្ជីឈ្មោះនេះមិនទាន់ត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាឯកសារភ័ស្តុតាងដែរ (ឯកសារ E393/3/1 កថាខណ្ឌ ១២, ១៣ ជើងទំព័រ ១៣)។ ទាក់ទិននឹងបញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ភាពជឿជាក់បាននៃឯកសារនេះមិនមានភាពច្បាស់លាស់ ដោយសារសហព្រះរាជអាជ្ញាធ្លាប់បានកែតម្រូវបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ខ្លួន ជាច្រើនលើកច្រើនសារ ។ ជាងនេះទៅទៀត ក.ស.ច.ស ដែលជាអង្គភាពតុលាការមួយរបស់ អ.វ.ត.ក បានបង្ហាញការមិនយល់ស្របទៅនឹងសេចក្តីសន្និដ្ឋានផ្សេងៗរបស់សហព្រះរាជអាជ្ញា ដោយបានកែតម្រូវបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ព (ឯកសារ E393/3/1 កថាខណ្ឌ ១៤)។ មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា បញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ គឺជាលទ្ធផលការងារផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ដែលមានសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ហេតុនេះហើយ

ឯកសារនេះមិនអាចទទួលយកជាឯកសារភ័ស្តុតាងបាននោះឡើយ។ ផ្ទុយទៅវិញ វាមានភាពសមស្របក្នុងការដាក់បញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ ភ្ជាប់ជាមួយនឹងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយល័ក្ខអក្សររបស់សហព្រះរាជអាជ្ញា ដោយសារអង្គជំនុំជម្រះ ធ្លាប់បានអនុវត្តបដិសេធមិនទទួលយកឯកសារនានា ដែលភាគីបានបង្កើតឡើង (ឯកសារ E393/3/1 កថាខណ្ឌ ១៥-១៧, ២០)។ មេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងផងដែរថា សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានផ្ទុយ ដែល (១) អះអាងថា ការកំណត់ចំនួនអ្នកជាប់ឃុំសរុបនៅមន្ទីរសន្តិសុខ ស-២១ គឺជាចំណុចសំខាន់ក្នុងការសម្រេចអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ និង (២) នៅពេលជាមួយគ្នានោះ នៅក្នុងបរិបទដោយឡែកមួយ បែរជាបដិសេធសារៈសំខាន់របស់អ្នកជំនាញផ្នែកប្រជាសាស្ត្រ ក្នុងការកំណត់អំពីចំនួនរងគ្រោះពិតប្រាកដនៅទូទាំងប្រទេសកម្ពុជា ដោយសារវាមិនមានផលប៉ះពាល់ទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទទៅវិញ (ឯកសារ E393/3/1 កថាខណ្ឌ ១៨-១៩)។ ភាគីផ្សេងទៀតមិនបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានោះឡើយ។

៦. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងទាំងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភ័ស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភ័ស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការ

វាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលឯកសារដែលបានស្នើសុំនេះ គឺជាភ័ស្តុតាងដោះបន្ទុក ដែលតម្រូវឲ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (*សូមមើល* ឯកសារ E319/36/2)។

៧. ជាបញ្ហាបឋម អង្គជំនុំជម្រះយល់ឃើញថាសំណើសុំឲ្យទទួលយកឯកសារពីសម័យខ្មែរក្រហមចំនួនបួននេះ លែងមានសារៈសំខាន់ទៀតហើយ ដោយសារឯកសារទាំងបួននេះត្រូវបានទទួលយកជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ រួចហើយ (*សូមមើល*ឯកសារ E3/8436, E3/8433, E3/8761, E3/8435)។

៨. អង្គជំនុំជម្រះយល់ឃើញថាបញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ មានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនាពេលនេះ និងជាការបំពេញបន្ថែមទៅលើបញ្ជីបឋមរបស់ ក.ស.ព និងបញ្ជីអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស ដែលត្រូវបានទទួលយកជាឯកសារភ័ស្តុតាងរួចហើយ។ ដូចបញ្ជីមុនៗដែរ បញ្ជីថ្មីនេះត្រូវបានចងក្រងដោយផ្អែកលើឯកសារនានាដែលជាភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ និងដែលត្រូវបានសន្និដ្ឋានថា បំពេញលក្ខខណ្ឌនៃភាពជឿជាក់បាន និងយថាភាព*តាមការវិភាគបឋម* រួចហើយ។ អង្គជំនុំជម្រះត្រូវធានាឲ្យមានការពិភាក្សាដេញដោលពេញលេញទៅលើភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង រួមទាំងភ័ស្តុតាងដែលត្រូវបានប្រើជាសំអាងទាំងនេះ និងបញ្ជីនានាដែលអង្គភាពតុលាការ ឬ ភាគីផ្ទាល់បានបង្កើតឡើង។ ផ្អែកលើសំអាងហេតុទាំងនេះ អង្គជំនុំជម្រះសម្រេចទទួលយកបញ្ជីឈ្មោះអ្នកជាប់ឃុំចំនួន ១៦០៦ នាក់ ធ្វើជាឯកសារភ័ស្តុតាង។

៩. ដើម្បីឲ្យមានភាពពេញលេញ តាមការផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសម្រេចទទួលយកឯកសារដែលមេធាវីការពារក្តី ខៀវ សំផន បានធ្វើការកត់សម្គាល់ (ឯកសារ D288/6.68.18) ធ្វើជាឯកសារភ័ស្តុតាងផងដែរ ដែលបានបំពេញទៅតាមលក្ខខណ្ឌក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និង ដាក់លេខយោងជាឯកសារ E3/10771។

១០. អនុស្សរណៈនេះ គឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E393/3។